អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះសាលាដំបូង

## សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្តី នួន ជា

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចស្តីពីកំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្តី នួន ជា។ សេចក្តីសម្រេចនេះ ដែលជាឯកសារសាធារណៈ និងត្រូវបានចេញបន្ទាប់ពីមានការព្រមានដោយផ្ទាល់មាត់មួយនៅក្នុងតុលាការនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ បានផ្តល់ជាឧទាហរណ៍ជាច្រើននៃកំហុសវិជ្ជាជីវៈរបស់មេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្តី នួន ជា ចំនួនពីររូប (លោក Michiel PESTMAN និង លោក Andrew IANUZZI)។ សេចក្តីសម្រេចនេះត្រូវចេញដោយមានទាំងការជូនដំណឹងទៅគណៈមេធាវី Amsterdam និងគណៈមេធាវីរដ្ឋ New York ដែលលោក PESTMAN និង លោក IANUZZI ជាសមាជិក ដើម្បីឲ្យគណៈមេធាវីទាំងពីរនេះដឹងអំពីកំហុសវិជ្ជាជីវៈនេះ និងចាត់វិធានការសមស្រប។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក៏បានទទួលដំណឹងអំពីអង្គហេតុនេះដែរ។ សេចក្តីសម្រេចនេះក៏បានគូសបញ្ជាក់អំពីផលវិបាកផ្សេងៗដែលអាចកើតមាន ដោយសារតែការចេញការព្រមាននេះ ដោយស្របតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។ វិធាន ៣៨ នៃវិធានផ្ទៃក្នុងបានផ្តល់អំណាចដល់អង្គជំនុំជម្រះសាលាដំបូង ឲ្យចាត់វិធានការផ្សេងៗនាពេលខាងមុខ ដោយឯករាជ្យពីគណៈមេធាវីនីមួយៗ ដោយវិធានការទាំងនោះអាចរួមទាំងការដាក់ទណ្ឌកម្ម ឬការបដិសេធការចូលរួមសវនាការរបស់មេធាវីណាម្នាក់នៃក្រុមមេធាវីការពារក្តី នួន ជា ដែលខកខានមិនបានយកចិត្តទុកដាក់ចំពោះការព្រមាននេះ។

កំហុសវិជ្ជាជីវៈដែលអង្គជំនុំជម្រះបានពណ៌នាពិស្តារនៅក្នុងសេចក្តីសម្រេច និងសេចក្តីជូនដំណឹងរបស់ខ្លួន ឆ្លុះបញ្ចាំងពីគំរូនៃការមិនយកចិត្តទុកដាក់ចំពោះមុខងារមេធាវីការពារក្តី និងចំពោះក្រមសីលធម៌វិជ្ជាជីវៈច្បាប់។ កំហុសវិជ្ជាជីវៈទាំងនេះរួមមាន:

- ការនិយាយស្តីនិងការប្រព្រឹត្តិដោយគ្មានការគោរពចំពោះតុលាការ និងការបង្អាក់កិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងសំណុំរឿង ០០២/០១។

- ការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានសម្ងាត់នានាដោយគ្មានការអនុញ្ញាត រួមទាំងការផ្សព្វផ្សាយដល់សារព័ត៌មានផងដែរ ដែលជាញឹកញាប់បានបង្ហាញចេញនូវចេតនាច្បាស់លាស់ក្នុងការធ្វើបែបនេះបន្តទៀតនាពេលខាងមុខ។ និង
- ការមិនគោរពបទបញ្ញត្តិនានានៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងសេចក្តីបង្គាប់នានារបស់អង្គជំនុំជម្រះសាលាដំបូង ដែលធ្វើឡើងដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ នួន ជា ហើយដែលអាចប៉ះពាល់ជាអវិជ្ជមានលើមេធាវីការពារក្តីរបស់ជនជាប់ចោទ។

មេធាវីដែលចូលរួមការពារក្តីនៅចំពោះមុខ អ.វ.ត.ក ត្រូវបានតម្រូវឲ្យ អនុលោមតាមមាត្រា ២១(៣) នៃកិច្ច ព្រមព្រៀង អ.វ.ត.ក និងច្បាប់កម្ពុជាជាធរមាន "សម្តែងជូនចៅក្រម ក្នុងភាពឯករាជ្យ និងភាពថ្លៃថ្នូរ នូវការគោរពទៅតាមមុខងាររបស់ខ្លួន"។ លោក PESTMAN និង លោក IANUZZI បានបង្ហាញឲ្យឃើញម្តងហើយម្តងទៀតនូវការមិនយកចិត្តទុកដាក់អំពីមុខងាររបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់នៅក្នុងសេចក្តីសម្រេច និងសេចក្តីជូនដំណឹងដែលអមជាមួយសេចក្តីសម្រេចនោះអំពីការប្រព្រឹត្តិដែលមានកម្រិតទាបជាងបទដ្ឋានវិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ និងមិនស្របជាមួយនឹងបទដ្ឋានដែលមានការទទួលស្គាល់និងក្រមសីលធម៌វិជ្ជាជីវៈផ្នែកច្បាប់។ បទដ្ឋានទាំងអស់នេះរួមមានការគោរពយ៉ាងត្រឹមត្រូវចំពោះស្ថាប័នយុត្តិធម៌ រួមទាំង អ.វ.ត.ក ក៏ដូចជាការគោរពចំពោះជនរងគ្រោះដោយសារឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរផងដែរ។ នេះជារឿងគួរឲ្យសោកស្តាយជាពិសេសនៅក្នុងបរិបទ អ.វ.ត.ក ដ៏ជាក់លាក់នេះ ដោយនៅទីនេះ មេធាវីអន្តរជាតិដែលត្រូវបានជួល ឬត្រូវបានផ្តល់ថវិកាដោយអង្គការសហប្រជាជាតិ ត្រូវគេរំពឹងទុកថានឹងបង្ហាញឲ្យឃើញនូវបទដ្ឋានអន្តរជាតិកម្រិតខ្ពស់បំផុត និងរួមចំណែកដល់ការកសាងសមត្ថភាពនៅក្នុងប្រទេសកម្ពុជា ព្រមទាំងការលើកស្ទួយសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះដោយសារបទល្មើសនានាដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងសម័យខ្មែរក្រហម។

ផ្នែកមួយនៃកំហុសវិជ្ជាជីវៈដែលកើតមានជាញឹកញាប់ ហើយត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការផ្សព្វផ្សាយឯកសារសម្ងាត់របស់តុលាការឲ្យទៅប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន (ពេលខ្លះនៅមុនពេលដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក) និងការផ្សព្វផ្សាយឯកសារផ្សេងទៀតដោយគ្មានការអនុញ្ញាត ឬមិនសមស្របសម្រាប់ចេញផ្សាយជាសាធារណៈ។ គោលបំណងមួយនៃសេចក្តីសម្រេចនេះ គឺដើម្បីធ្វើការណែនាំដល់តំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អំពីផលប៉ះពាល់ដែលអាចកើតមានឡើងដោយសារតែការបញ្ចេញឯកសារសម្ងាត់ដោយគ្មានការអនុញ្ញាត ទៅលើសន្តិសុខរបស់ជនរងគ្រោះនិងសាក្សីនានា ក៏ដូចជាទៅលើផលប្រយោជន៍នៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ដែលត្រូវការពារ។ សេចក្តីសម្រេចនេះអាចជួយដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកម្ពុជានិងអន្តរជាតិ

ឲ្យធ្វើការសាកសួរឲ្យបានច្បាស់ ថាតើឯកសារដែលក្រុមមេធាវីការពារក្ដី នួន ជា បានផ្ដល់ឲ្យពួកគាត់ជាឯកសារសមស្របសម្រាប់ចុះផ្សាយដែរឬទេ។

តំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងឡាយដែលមានបំណងពិនិត្យផ្ទៀងផ្ទាត់ថាតើឯកសារដែលបានផ្ដល់ឲ្យពួកគាត់គឺជាឯកសារសាធារណៈជាផម្ពាន្ធរូបដែរឬទេនោះ អាចទាក់ទងមកមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ (តាមរយៈផ្នែកកិច្ចការសាធារណៈ អ.វ.ត.ក) ដើម្បីទទួលបានការឆ្លើយតបលើផ្នែកនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ 0២៣
សារអេឡិកត្រូនិក: olsenl@un.org